ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៤ អនុក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ឯកសណ្ឋាននិងបណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៤/០០៨ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីផ្លូវថ្នល់
- បានឃើញអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ/.

- បានឃើញអនុក្រឹត្យលេខ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ៥១ អនក្រ.បក ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០១ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ១៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងដីចំណីតាមបណ្តាញផ្លូវជាតិនិងផ្លូវរថភ្លើងនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៣ ស្តីពីបែបបទនិងនីតិវិធីនៃការដាក់ឈ្មោះផ្លូវឬលេខផ្លូវ និងការកែប្រែឈ្មោះផ្លូវឬលេខផ្លូវ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះកំណត់នូវឯកសណ្ឋាន សញ្ញាសក្តិ មួក សញ្ញាសម្គាល់ និងបណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់ សម្រាប់ប្រើប្រាស់បំពេញការងារចុះអនុវត្តច្បាប់ស្តីពីផ្លូវថ្នល់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងច្បាប់ស្តីពីផ្លូវថ្នល់ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

អធិការកិច្ចផ្លូវថ្នល់ សរសេរជាអក្សរកាត់ថា **អ.ក.ផ.ថ.**។

## ជំពូកទី២

## ឯកសណ្ឋាន សញ្ញាសក្តិ និងមួក

### ផ្នែកទី១

### ឯកសណ្ឋាន

**មាត្រា២.-**

ឯកសណ្ឋានរបស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់ ត្រូវបានកំណត់ជា២(ពីរ)ថ្នាក់ ដូចខាងក្រោម៖

១- ថ្នាក់អគ្គនាយក អគ្គនាយករង ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ អនុប្រធានការិយាល័យនិងមន្ត្រីផ្សេងទៀត។

ក- ឯកសណ្ឋានបុរស

- អាវដៃខ្លីពណ៌កាគី កបើក ថ្នេរឌុប ប៉ូលស្មាសងខាង ដឹបចង្កេះ សម្រុងជើងអាវត្រង់ស្មើ ចែកពីក្រោយសងខាងតាមបណ្តោយខ្លួនប្រវែង២៥ស.ម. ហើយមានប៊ូតុងចំនួនបួន ហោប៉ៅខាងលើដេរបត់ផ្នត់កណ្តាលមានគម្របរាងស្លឹកពោធិ៍ ហោប៉ៅខាងក្រោមដេរផ្ទាត់ ប៉ះផ្នត់កណ្តាលមានគម្របរាងស្លឹកពោធិ៍ និងឡេវមានត្រារូបព្រះស[illegible]

- អាវដៃវែងពណ៌កាគី កបើក ថ្នេរឌុប ប៉ូលស្មាសងខាង ដឹបភ្លីខាងមុខពីរ ឡេវធំមានត្រារូបព្រះសង្ខារពណ៌មាសពីក្រោមហូតដល់លើ សម្រុងជើងអាវត្រង់ស្មើ ផែកពីក្រោយសងខាងតាមបណ្ដោយខ្លួនប្រវែង២៥ស.ម. ហើយមានហោប៉ៅចំនួនបួន ហោប៉ៅខាងលើដេរបត់ផ្នត់កណ្ដាលមានគម្របរាងស្លឹកពោធិ៍ ហោប៉ៅខាងក្រោមដេរគ្មានផ្នត់កណ្ដាលមានគម្របរាងចតុកោណកែង ផ្នែកខាងក្រោយមានដឹបភ្លីចំនួនពីរ និងមានផែកចំកណ្ដាលនៃអាវ។ អាវដៃវែងនេះពាក់ពីខាងក្រៅ ហើយចំពោះអាវខាងក្នុង គឺអាវសឺមីពណ៌សដៃវែង ក្រវាត់កពណ៌លឿងចាស់ សម្រាប់ប្រើក្នុងពិធីការតែប៉ុណ្ណោះ
- ខោជើងវែងពណ៌កាគី ដេរថ្នេរបង្កប់ ចង្កេះត ដឹបភ្លីខាងមុខពីរ មានហោប៉ៅចំនួនបី ហោប៉ៅខាងក្រោយមួយដេរបង្កប់មានគម្របរាងស្លឹកពោធិ៍ ចោះរន្ធដាក់ឡេវចំនួនមួយ និងហោប៉ៅចំហៀងទាំងសងខាងដេរបង្កប់តាមថ្នេរ
- ស្បែកជើងពណ៌ខ្មៅ ស្រោមជើងពណ៌ខ្មៅ
- ខ្សែក្រវាត់ពណ៌ខ្មៅ។

ខ- ឯកសណ្ឋាននារី

- អាវម៉ូដដូចបុរស ប៉ុន្តែកអាវមានរាងកអាវរបស់ស្ត្រី
- ខោម៉ូដដូចបុរស ប៉ុន្តែគ្មានហោប៉ៅក្រោយ មានពណ៌កាគី ឬសំពត់ហ្ស៊ីបពណ៌កាគី សម្រុងក្រោមជង្គង់ ផែកក្រោយ រូតចំហៀង
- ស្បែកជើងពណ៌ខ្មៅ ស្រោមជើងពណ៌ខ្មៅ
- ខ្សែក្រវាត់ពណ៌ខ្មៅ។

រូបគំរូនៃឯកសណ្ឋាននេះ មានដូចក្នុងឧបសម្ព័ន្ធទី១។

២- ថ្នាក់ភ្នាក់ងារ។

ក. ឯកសណ្ឋានបុរស

- អាវដៃខ្លីពណ៌កាគី កឌុប ថ្នេរឌុប ចោះឡេវចុងក ប៉ូលស្មាសងខាង ហោប៉ៅពីរដេរបត់ផ្នត់កណ្ដាលមានគម្របរាងស្លឹកពោធិ៍ កាត់ស្រុងវែង ជើងត្រង់ដាក់ក្នុងខោ ហើយឡេវពីមុខនិងឡេវហោប៉ៅមានពណ៌ដូចអាវ
- អាវដៃវែងពណ៌កាគី កបើក ថ្នេរឌុប ប៉ូលស្មាសងខាង ដឹបភ្លីខាងមុខពីរ ឡេវធំមានត្រារូបព្រះសង្ខារពណ៌ប្រាក់ពីក្រោមហូតដល់លើ សម្រុងជើងអាវត្រង់ស្មើ ផែកពីក្រោយសងខាងតាមបណ្ដោយខ្លួនប្រវែង២៥ស.ម. ហើយមានហោប៉ៅចំនួនបួន ហោប៉ៅខាងលើដេរបត់ ផ្នត់កណ្ដាលមានគម្របរាងស្លឹកពោធិ៍ ហោប៉ៅខាងក្រោមដេរគ្មានផ្នត់ កណ្ដាលមានគម្រប រាងចតុកោណកែង ផ្នែកខាងក្រោយមានដឹបភ្លីចំនួនពីរ និងមានផែកចំកណ្ដាលនៃអាវ។ អាវដៃវែងនេះពាក់ពីខាងក្រៅ ហើយចំពោះអាវខាងក្នុង គឺអាវសឺមីពណ៌ផ្ទៃមេឃដៃវែង ក្រវាត់កពណ៌លឿងចាស់សម្រាប់ប្រើក្នុងពិធីការតែប៉ុណ្ណោះ
- ខោជើងវែងពណ៌កាគី ដេរថ្នេរបង្កប់ ចង្កេះត ដឹបភ្លីខាងមុខពីរ មានហោប៉ៅបី ហោប៉ៅខាងក្រោយមួយដេរបង្កប់មានគម្របរាងស្លឹកពោធិ៍ចោះរន្ធដាក់ឡេវចំនួនមួយ និងហោប៉ៅចំហៀងទាំងសងខាងដេរបង្កប់តាមថ្នេរ
- ស្បែកជើងពណ៌ខ្មៅ ស្រោមជើងពណ៌ខ្មៅ
- ខ្សែក្រវាត់ពណ៌ខ្មៅ។/.

ខ. ឯកសណ្ឋាននារី
- អាវម៉ូដដូចបុរស ប៉ុន្តែកអាវមានរាងកអាវរបស់ស្ត្រី
- ខោម៉ូដដូចបុរស ប៉ុន្តែគ្មានហោប៉ៅក្រោយ មានពណ៌កាគី ឬសំពត់ហ៊ីបពណ៌កាគីកាត់ក្រោមជង្គង់ ផែកក្រោយ រូតចំហៀង
- ស្បែកជើងពណ៌ខ្មៅ ស្រោមជើងពណ៌ខ្មៅ
- ខ្សែក្រវ៉ាត់ពណ៌ខ្មៅ ។

## ផ្នែកទី២
## សញ្ញាសក្តិ

**មាត្រា៣ ..**

សញ្ញាសក្តិស្មា ត្រូវមានបាតក្រោមប្រវែង៦(ប្រាំមួយ)សង់ទីម៉ែត្រ បណ្តោយពីលើបាតក្រោមប្រវែង១៣(ដប់បី)សង់ទីម៉ែត្រ និងមានទទឹងមុខកាត់ផ្នែកខាងលើប្រវែង៤,៧សង់ទីម៉ែត្រ មានរាងកោងជាមុំទាល។

សញ្ញាសក្តិស្មា ត្រូវបានរៀបចំជា៨(ប្រាំបី)ថ្នាក់ខុសៗគ្នា សម្រាប់សម្គាល់ថ្នាក់អគ្គនាយក ថ្នាក់អគ្គនាយករង ថ្នាក់ប្រធាននាយកដ្ឋាន ថ្នាក់អនុប្រធាននាយកដ្ឋាន ថ្នាក់ប្រធានការិយាល័យ ថ្នាក់អនុប្រធានការិយាល័យ ថ្នាក់មន្ត្រី ថ្នាក់ភ្នាក់ងារ៖

**១- ថ្នាក់អគ្គនាយក :** មានផ្ទៃពណ៌ស ក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញ ប៉ាក់អក្សរ **"អ.ភ.ផ.ថ."** ពណ៌មាស មានក្បាច់អង្គរពណ៌មាសទំហំធំទ្រខាងក្រោម មានសញ្ញាអធិការកិច្ចផ្លូវថ្នល់របស់សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់រាងមូលនៅចំកណ្តាល និងមានរូបព្រះសង្ការពណ៌មាសនៅខាងចុងនៃសញ្ញាសក្តិ។ រូបគំរូនៃសញ្ញាសក្តិនេះ មានដូចក្នុងឧបសម្ព័ន្ធទី២។

**២- ថ្នាក់អគ្គនាយករង :** មានផ្ទៃពណ៌ស ក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញ ប៉ាក់អក្សរ **"អ.ភ.ផ.ថ."** ពណ៌មាស មានក្បាច់អង្គរពណ៌មាសទំហំតូចទ្រខាងក្រោម មានសញ្ញាអធិការកិច្ចផ្លូវថ្នល់របស់សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់រាងមូលនៅចំកណ្តាល និងមានរូបព្រះសង្ការពណ៌មាសនៅខាងចុងនៃសញ្ញាសក្តិ។ រូបគំរូនៃសញ្ញាសក្តិនេះ មានដូចក្នុងឧបសម្ព័ន្ធទី៣។

**៣- ថ្នាក់ប្រធាននាយកដ្ឋាន :** មានផ្ទៃពណ៌ស នៅផ្នែកខាងក្រោមបង្អស់មានចម្លាក់ក្បាច់អង្គរពណ៌មាសទំហំធំ នៅខាងលើក្បាច់នេះមានប៉ាក់អក្សរ **"អ.ភ.ផ.ថ."** ពណ៌មាស នៅខាងលើអក្សរមានសញ្ញាអធិការកិច្ចផ្លូវថ្នល់របស់សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់រាងមូល នៅចំកណ្តាលមានរូបព្រះសង្ការពណ៌មាសនៅខាងចុងនៃសញ្ញាសក្តិ មានក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញហើយមានខ្សែព្យួរវេញ៣(បី)ខ្សែពណ៌មាសព័ទ្ធជុំវិញខាងក្រៅ។ រូបគំរូនៃសញ្ញាសក្តិនេះ មានដូចក្នុងឧបសម្ព័ន្ធទី៤។

**៤- ថ្នាក់អនុប្រធាននាយកដ្ឋាន :** មានផ្ទៃពណ៌ស នៅផ្នែកខាងក្រោមបង្អស់មានចម្លាក់ក្បាច់អង្គរពណ៌មាសទំហំតូច នៅខាងលើក្បាច់នេះមានប៉ាក់អក្សរ **"អ.ភ.ផ.ថ."**ពណ៌មាស នៅខាងលើអក្សរមានសញ្ញាអធិការកិច្ចផ្លូវថ្នល់របស់សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់រាងមូលនៅចំកណ្តាល មានរូបព្រះសង្ការពណ៌មាសនៅខាងចុងនៃសញ្ញាសក្តិ មានក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញ ហើយមានខ្សែព្យួរវេញ២(ពីរ)ខ្សែពណ៌មាសព័ទ្ធជុំវិញខាងក្រៅ។ រូបគំរូនៃសញ្ញាសក្តិនេះ មានដូចក្នុងឧបសម្ព័ន្ធទី៥។

៥- ថ្នាក់ប្រធានការិយាល័យ : មានផ្ទៃពណ៌ស នៅផ្នែកខាងក្រោមបង្កស់មានចម្លាក់ក្បាច់អង្គរពណ៌មាសទំហំតូច នៅលើក្បាច់នេះមានប៉ាក់អក្សរ "អ.ក.ផ.ថ." ពណ៌មាស នៅខាងលើអក្សរមានសញ្ញាអធិការកិច្ចផ្លូវថ្នល់របស់សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់រាងមូលនៅចំកណ្តាល មានរូបព្រះសង្ការពណ៌មាសនៅខាងចុងនៃសញ្ញាសក្តិ មានក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញហើយមានខ្សែពួរវេញ១(មួយ)ខ្សែពណ៌មាសព័ទ្ធជុំវិញខាងក្រៅ។ រូបគំរូនៃសញ្ញាសក្តិនេះ មានដូចក្នុងឧបសម្ព័ន្ធទី៦។

៦- ថ្នាក់អនុប្រធានការិយាល័យ : មានផ្ទៃពណ៌ស នៅផ្នែកខាងក្រោមបង្កស់មានចម្លាក់ក្បាច់អង្គរពណ៌មាសទំហំតូច នៅលើក្បាច់នេះមានប៉ាក់អក្សរ "អ.ក.ផ.ថ." ពណ៌ប្រាក់ នៅខាងលើអក្សរមានសញ្ញាអធិការកិច្ចផ្លូវថ្នល់របស់សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់រាងមូលនៅចំកណ្តាល មានរូបព្រះសង្ការពណ៌មាសនៅខាងចុងនៃសញ្ញាសក្តិ មានក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញ ហើយមានខ្សែពួរវេញ១(មួយ) ខ្សែពណ៌មាសព័ទ្ធជុំវិញខាងក្រៅ។ រូបគំរូនៃសញ្ញាសក្តិនេះមានដូចក្នុងឧបសម្ព័ន្ធទី៧។

៧- ថ្នាក់មន្ត្រី : មានផ្ទៃពណ៌ស នៅផ្នែកខាងក្រោមបង្កស់មានចម្លាក់ក្បាច់អង្គរពណ៌ប្រាក់ទំហំតូច នៅលើក្បាច់នេះមានប៉ាក់អក្សរ "អ.ក.ផ.ថ." ពណ៌ប្រាក់ នៅខាងលើអក្សរមានសញ្ញាអធិការកិច្ចផ្លូវថ្នល់របស់សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់រាងមូលនៅចំកណ្តាល មានរូបព្រះសង្ការពណ៌ប្រាក់នៅខាងចុងនៃសញ្ញាសក្តិ មានក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញ ហើយមានខ្សែពួរវេញ១(មួយ)ខ្សែពណ៌មាសព័ទ្ធជុំវិញខាងក្រៅ។ រូបគំរូនៃសញ្ញាសក្តិនេះ មានដូចក្នុងឧបសម្ព័ន្ធទី៨។

៨- ថ្នាក់ភ្នាក់ងារ : មានផ្ទៃពណ៌ស នៅផ្នែកខាងក្រោមបង្កស់មានចម្លាក់ក្បាច់អង្គរពណ៌ប្រាក់ ទំហំតូច នៅលើក្បាច់នេះមានប៉ាក់អក្សរ "អ.ក.ផ.ថ." ពណ៌ប្រាក់ នៅខាងលើអក្សរមានសញ្ញាអធិការកិច្ចផ្លូវថ្នល់របស់សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់រាងមូលនៅចំកណ្តាល មានរូបព្រះសង្ការពណ៌ប្រាក់ នៅខាងចុងនៃសញ្ញាសក្តិមានក្បាច់ភ្ញីទេសពណ៌ប្រាក់ព័ទ្ធជុំវិញ ហើយមានខ្សែពួរវេញ១(មួយ)ខ្សែពណ៌ប្រាក់ព័ទ្ធជុំវិញខាងក្រៅ។ រូបគំរូនៃសញ្ញាសក្តិនេះ មានដូចក្នុងឧបសម្ព័ន្ធទី៩។

## ផ្នែកទី៣

## មួក

**មាត្រា៤ .-**

មួកកាស្កែត ត្រូវបានរៀបចំជា៦(ប្រាំមួយ)ថ្នាក់៖

១- ថ្នាក់អគ្គនាយក : មួកកាស្កែតធ្វើពីក្រណាត់ពណ៌ដូចអាវ ផ្នែកខាងមុខលើកណ្តាប់វណ្ណមានភ្ជាប់រូបព្រះសង្ការពណ៌មាសទំហំកម្ពស់៧,៨ស.ម. ទទឹង៦,៨ស.ម. ផ្នែកខាងក្រោមនៃជើងមួកនិងក្រោមព្រះសង្ការមានក្បាច់ភ្ញីទេសប៉ាក់ពណ៌មាសដល់ជើងមួក និងខាងក្រោមក្បាច់មានប៉ាក់វណ្ណពួរពណ៌មាសពីលើក្រណាត់ខ្សែនពណ៌កាគីព័ទ្ធជុំវិញ ព្រមទាំងនៅខាងចុងខ្សែវណ្ណទាំងពីរខាងមានភ្ជាប់ឡេវរូបព្រះសង្ការពណ៌មាស។ ខាងក្រោមនៃប៉ាក់វណ្ណផ្នែកខាងមុខមានក្បាំងពណ៌ខ្មៅ នៅលើក្បាំងមានប៉ានក្បាច់ភ្ញីទេសប៉ាក់ពណ៌មាសទម្រង់ស្នែងក្របីធំដល់ជើងមួក។

២- ថ្នាក់អគ្គនាយករង : មួកកាស្កែតធ្វើពីក្រណាត់ពណ៌ដូចអាវ ផ្នែកខាងមុខលើកណ្តាប់វណ្ណមានភ្ជាប់រូបព្រះសង្ការពណ៌មាសទំហំកម្ពស់៧,៨ស.ម. ទទឹង៦,៨ស.ម. ផ្នែកខាងក្រោមនៃជើងមួកនិងក្រោមព្រះសង្ការមានប៉ាក់វណ្ណពួរពណ៌មាសពីក្រណាត់ខ្សែនពណ៌កាគីព័ទ្ធជុំវិញ ព្រម...

ខាងចុង ខ្សែវណ្ណទាំងពីរខាងភ្ជាប់ដោយឡេវរូបព្រះសង្ហារពណ៌មាស។ ខាងក្រោមនៃប៉ាក់វណ្ណផ្នែកខាងមុខមានក្បាំងពណ៌ខ្មៅ នៅលើក្បាំងមានប៉ានក្បាច់ភ្ញីទេសប៉ាក់ពណ៌មាសទម្រង់ស្នែងក្របីធំដល់ជើងមួក។

៣- ថ្នាក់ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន : មួកកាស្កែតធ្វើពីក្រណាត់ពណ៌ដូចអាវ ផ្នែកខាងមុខលើកណ្តាប់វណ្ណមានភ្ជាប់រូបព្រះសង្ហារពណ៌មាសទំហំកម្ពស់៧,៨ស.ម. ទទឹង៦,៨ស.ម. ផ្នែកខាងក្រោមនៃជើងមួកនិងក្រោមព្រះសង្ហារមានកណ្តាប់វណ្ណពណ៌មាសនៅពីលើក្រណាត់ខ្សែនពណ៌កាគីព័ទ្ធជុំវិញ។ ខាងក្រោមកណ្តាប់វណ្ណផ្នែកខាងមុខមានក្បាំងពណ៌ខ្មៅ។ ផ្នែកខាងក្រោមកណ្តាប់វណ្ណដែលនៅពីលើក្បាំងមានកម្រងខ្សែសយពណ៌មាសនៅខាងចុងកម្រង ខ្សែសយទាំងពីរខាងមានភ្ជាប់ឡេវព្រះសង្ហារពណ៌មាស។ នៅលើក្បាំងមួកមានប៉ានក្បាច់ភ្ញីទេសប៉ាក់ពណ៌មាសទម្រង់ស្នែងក្របីធំដល់ជើងមួក។

៤- ប្រធានការិយាល័យ អនុប្រធានការិយាល័យ : មួកកាស្កែតធ្វើពីក្រណាត់ពណ៌ដូចអាវ ផ្នែកខាងមុខលើកណ្តាប់វណ្ណមានភ្ជាប់រូបព្រះសង្ហារពណ៌មាសទំហំកម្ពស់៧,៨ស.ម. ទទឹង៦,៨ស.ម. ផ្នែកខាងក្រោមនៃជើងមួកនិងក្រោមព្រះសង្ហារមានកណ្តាប់វណ្ណពណ៌មាសធ្វើពីលើក្រណាត់ខ្សែនពណ៌កាគីព័ទ្ធជុំវិញ។ ខាងក្រោមកណ្តាប់វណ្ណផ្នែកខាងមុខមានក្បាំងពណ៌ខ្មៅ។ ផ្នែកខាងក្រោមកណ្តាប់វណ្ណ ដែលនៅពីលើក្បាំងមានកម្រងខ្សែសយពណ៌មាស ព្រមទាំងនៅសងខាងចុងខ្សែទាំងពីរខាងភ្ជាប់ដោយឡេវព្រះសង្ហារពណ៌មាស។ នៅលើក្បាំងមួកមានប៉ានក្បាច់ភ្ញីទេសប៉ាក់ពណ៌មាសទម្រង់ស្នែងក្របីដោយ ចុងសងខាងទុកចន្លោះ៤(បួន)ស.ម. ពីជើងមួក។

៥- ថ្នាក់មន្ត្រី : មួកកាស្កែតធ្វើពីក្រណាត់ពណ៌ដូចអាវ ផ្នែកខាងមុខលើកណ្តាប់វណ្ណមានភ្ជាប់រូបព្រះសង្ហារពណ៌មាសទំហំកម្ពស់៧,៨ស.ម. ទទឹង៦,៨ស.ម. ផ្នែកខាងក្រោមនៃជើងមួកនិងក្រោមព្រះសង្ហារមានកណ្តាប់វណ្ណពណ៌មាសធ្វើពីលើក្រណាត់ខ្សែនពណ៌កាគីព័ទ្ធជុំវិញ។ ខាងក្រោមកណ្តាប់វណ្ណផ្នែកខាងមុខមានក្បាំងពណ៌ខ្មៅ។ ផ្នែកខាងក្រោមកណ្តាប់វណ្ណដែលនៅពីលើក្បាំងមានកម្រងខ្សែសយពណ៌មាស ព្រមទាំងនៅសងខាងចុងខ្សែទាំងពីរខាងភ្ជាប់ដោយឡេវព្រះសង្ហារពណ៌មាស។ នៅលើក្បាំងមួកគ្មានប៉ានក្បាច់ភ្ញីទេសទេ។

៦- ថ្នាក់ភ្នាក់ងារ : មួកកាស្កែតធ្វើពីក្រណាត់ពណ៌ដូចអាវ ផ្នែកខាងមុខលើកណ្តាប់វណ្ណមានភ្ជាប់រូបព្រះសង្ហារពណ៌ប្រាក់ទំហំកម្ពស់៧,៨ស.ម. ទទឹង៦,៨ស.ម. ផ្នែកខាងក្រោមនៃជើងមួកនិងក្រោមព្រះសង្ហារមានកណ្តាប់វណ្ណពណ៌មាសធ្វើពីលើក្រណាត់ខ្សែនពណ៌កាគីព័ទ្ធជុំវិញ។ ខាងក្រោមកណ្តាប់វណ្ណផ្នែកខាងមុខមានក្បាំងពណ៌ខ្មៅ។ ផ្នែកខាងក្រោមកណ្តាប់វណ្ណដែលនៅពីលើក្បាំងមានកម្រងខ្សែសយពណ៌ប្រាក់ ព្រមទាំងនៅសងខាងចុងខ្សែទាំងពីរខាងភ្ជាប់ដោយឡេវព្រះសង្ហារពណ៌ប្រាក់។ នៅលើក្បាំងមួកគ្មានប៉ានក្បាច់ភ្ញីទេសទេ។ រូបគំរូនៃមួកខាងលើនេះ មានដូចក្នុងឧបសម្ព័ន្ធទី១០។

## ជំពូកទី៣
## សញ្ញាសម្គាល់

**មាត្រា៥ ..**

សញ្ញាពាក់នៅលើដៃអាវខាងស្តាំ ជាសញ្ញានិមិត្តរូបរបស់សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ ធ្វើអំពីក្រណាត់សំពត់ក្រាស់រាងជារង្វង់មានអង្កត់ផ្ចិតប្រវែង៨ស.ម.។៚

**មាត្រា៦ .-**

សញ្ញាសម្គាល់របស់អធិការកិច្ចផ្លូវថ្នល់មានរាងមូលប៉ោងទំហំ៤,៧ស.ម. ធ្វើអំពីស្ពាន់ភ្ជាប់ដោយបន្ទះស្បែកសម្រាប់ពាក់នៅលើហោប៉ៅអាវស្តាំ។

សញ្ញាសម្គាល់រួមមានសញ្ញានិមិត្តរូបរបស់សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ ដែលព័ទ្ធជុំវិញដោយពាក់កណ្តាលខាងលើជាអក្សរខ្មែរ "អធិការកិច្ចផ្លូវថ្នល់" និងពាក់កណ្តាលខាងក្រោមជាអក្សរអង់គ្លេស "Inspector of Roads"។

**មាត្រា៧ .-**

សញ្ញាសម្រាប់ប៉ាក់ជាប់ចុងកអាវរបស់អធិការកិច្ចផ្លូវថ្នល់ ជាសញ្ញានិមិត្តរូបរបស់សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់។

**មាត្រា៨ .-**

ស្លាកសម្គាល់ឈ្មោះមន្ត្រី សម្រាប់ពាក់នៅពីលើហោប៉ៅអាវខាងស្តាំមានរាងចតុកោណកែងដែលមានបណ្តោយប្រវែង៩,៥ស.ម. ទទឹង២,០ស.ម. ដែលសរសេរអក្សរពណ៌ទឹកមាស និងពាសដោយជ័រវែងថ្លាមានផ្ទៃពណ៌ខ្មៅ និងមានខ្សែបន្ទាត់ស្តើងពណ៌មាសព័ទ្ធជុំវិញ ដែលមានទំហំ០,១៥ស.ម.។ ប៉ែកខាងស្តាំដៃនៃស្លាកឈ្មោះមានសញ្ញានិមត្តរូបរបស់សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ និងប៉ែកខាងឆ្វេងមានសរសេរគោត្តនាមនិងនាមជាអក្សរខ្មែរ អក្សរឡាតាំង និងមានអត្តលេខរបស់មន្ត្រីរាជការ។

**មាត្រា៩ .-**

ឯកសណ្ឋាន សញ្ញាសក្តិ មួក និងសញ្ញាសម្គាល់ដូចមានចែងក្នុងអនុក្រឹត្យនេះ ត្រូវបានផ្តល់ដល់មន្ត្រីម្នាក់ៗចំនួន២(ពីរ)កំប្លេ នូវឯកសណ្ឋានខ្លីឬវែង សម្រាប់ប្រើប្រាស់ក្នុងរយៈពេល១(មួយ)ឆ្នាំ។

## ជំពូកទី៤
## បណ្ណសម្គាល់ខ្លួន

**មាត្រា១០ .-**

មន្ត្រីអធិការកិច្ចផ្លូវថ្នល់ ត្រូវមានបណ្ណសម្គាល់ខ្លួនដើម្បីបញ្ជាក់អត្តសញ្ញាណក្នុងពេលបំពេញភារកិច្ច ដែលចេញដោយសមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់។

បណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់ ត្រូវមានអត្តលេខ ឈ្មោះ បិទរូបថត ចុះហត្ថលេខា និងបោះត្រាជាផ្លូវការរបស់សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់។

**មាត្រា១១ .-**

មន្ត្រីអធិការកិច្ចផ្លូវថ្នល់ ត្រូវស្លៀកពាក់ឯកសណ្ឋាន សញ្ញាសក្តិ មួក សញ្ញាសម្គាល់ បណ្ណសម្គាល់ខ្លួន និងលិខិតបញ្ជាបេសកកម្ម ឬលិខិតឧទ្ទេសនាម ក្នុងពេលបំពេញបេសកកម្ម។ ក្នុងពិធីប្រជុំឬពិធីការផ្សេងៗទៀត បើចាំបាច់ត្រូវស្លៀកពាក់ឯកសណ្ឋាន សញ្ញាសក្តិ មួក និងសញ្ញាសម្គាល់ ដូចមានចែងក្នុងអនុក្រឹត្យនេះ។

**មាត្រា១២ .-**

ជនណាក្លែងបន្លំ ដោយស្លៀកពាក់ឯកសណ្ឋាន សញ្ញាសក្តិឬសញ្ញាសម្គាល់ ឬបណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់ ដូចមានកំណត់ក្នុងអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា១៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន**

**ត្រាំ អ៊ីវតឹក**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

នៃអនុក្រឹត្យលេខ.៤៧៤...អនុក្រ.បក.........ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០១៥
ស្តីពីឯកសណ្ឋាននិងបណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់

## ឯកសណ្ឋានសម្រាប់បំពេញបេសកកម្ម



## ឯកសណ្ឋានសម្រាប់ចូលរួមពិធីប្រជុំឬពិធីការផ្សេងៗ



## ឧបសម្ព័ន្ធទី២

## នៃអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០១៥

## ស្តីពីឯកសណ្ឋាននិងបណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់

### សញ្ញាសក្តិសម្រាប់ថ្នាក់អគ្គនាយក



# ឧបសម្ព័ន្ធទី៣

## នៃអនុក្រឹត្យលេខ.២៤..អនក្រ.បក ចុះថ្ងៃទី.១០... ខែ...មីនា.... ឆ្នាំ២០១៥

## ស្តីពីឯកសណ្ឋាននិងបណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់

### សញ្ញាសក្តិសម្រាប់អគ្គនាយករង



## ឧបសម្ព័ន្ធទី៤

នៃអនុក្រឹត្យលេខ ២៨៤ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០១៥

ស្តីពីឯកសណ្ឋាននិងបណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់

### សញ្ញាសក្តិសម្រាប់ប្រធាននាយកដ្ឋាន



# ឧបសម្ព័ន្ធទី៥

## នៃអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១០ ខែ ០៣ ឆ្នាំ២០១៥

## ស្តីពីឯកសណ្ឋាននិងបណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់

### សញ្ញាសក្តិសម្រាប់អនុប្រធាននាយកដ្ឋាន



# ឧបសម្ព័ន្ធទី៦

## នៃអនុក្រឹត្យលេខ៧៤ អនក្រ.បក ចុះថ្ងៃទី១០ ខែមិនា ឆ្នាំ២០១៥

## ស្តីពីឯកសណ្ឋាននិងបណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់

### សញ្ញាសក្តិសម្រាប់ប្រធានការិយាល័យ



# ឧបសម្ព័ន្ធទី៧

## នៃអនុក្រឹត្យលេខ ២៨.អន.ក្រ.បក ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០១៥

## ស្តីពីឯកសណ្ឋាននិងបណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់

## សញ្ញាសក្តិសម្រាប់អនុប្រធានការិយាល័យ



## ឧបសម្ព័ន្ធទី៨

### នៃអនុក្រឹត្យលេខ ២៧៤ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០១៥

### ស្តីពីឯកសណ្ឋាននិងបណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់

សញ្ញាសក្តិសម្រាប់មន្ត្រី



# ឧបសម្ព័ន្ធទី៩

**នៃអនុក្រឹត្យលេខ..២៤..អនក្រ.បក..ចុះថ្ងៃទី..១០.... ខែ..មីនា..... ឆ្នាំ២០១៥**

**ស្តីពីឯកសណ្ឋាននិងបណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់**

**សញ្ញាសក្តិសម្រាប់ត្អាក់ខារ**



# ឧបសម្ព័ន្ធទី១០

## នៃអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ២០១៥

## ស្តីពីឯកសណ្ឋាននិងបណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់

### មួកការស្កេត

| | |
|---|---|
|  | មួកការស្កេត សម្រាប់ថ្នាក់អគ្គនាយក |
|  | មួកការស្កេត សម្រាប់អគ្គនាយករង |
|  | មួកការស្កេត សម្រាប់ប្រធាន អនុប្រធាននាយកដ្ឋាន |
|  | មួកការស្កេត សម្រាប់ប្រធាន អនុប្រធានការិយាល័យ |
|  | មួកការស្កេត មន្ត្រីផ្សេងទៀត |
|  | មួកការស្កេត មន្ត្រីឆ្លាក់ខារ |